សហភាពអឺរ៉ុប

actionaid

# បទបង្ហាញសង្ខេបថ្នាក់គោលនយោបាយក្នុងវិស័យដី ប្រៀបធៀបជាមួយ គោលការណ៍ណែនាំ ដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការ កាន់កាប់ដី ជលផល និងព្រៃឈើ "ភាពស្របគ្នា គម្លាត បញ្ហាប្រឈមសំខាន់ៗ និងផ្លូវឆ្ពោះទៅមុខ"

*ដោយមេធាវី សេក សោភ័ណ (១៧ ធ្នូ ២០១៨)*

*បទបង្ហាញសង្ខេបថ្នាក់គោលនយោបាយនេះឈរលើមូលដ្ឋាននៃរបាយការណ៍ស្តីពី " ការពិនិត្យឡើងវិញនូវច្បាប់ និងក្របខណ្ឌកម្ពុជាលើវិស័យដី ជលផលនិងព្រៃឈើ ប្រៀបធៀបជាមួយ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ "ភាពស្របគ្នា គម្លាត បញ្ហាប្រឈម សំខាន់ៗ និងផ្លូវឆ្ពោះទៅមុខ" អង្គការ ActionAid & NGO Forum on Cambodia, ខែវិច្ឆិកា ឆ្នាំ ២០១៨។*

ក្របខណ្ឌគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ការកាន់កាប់ដី ឬភោគៈស្របច្បាប់លើដីថាជាលទ្ធកម្ម ដែលអាចស្នើសុំជាដីកម្មសិទ្ធិបាន។ ភោគៈស្របច្បាប់ត្រូវបានកំណត់លក្ខខណ្ឌ ដោយច្បាប់ភូមិបាលឆ្នាំ ២០០១ និងត្រូវបានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ លទ្ធកម្មកម្មសិទ្ធិ តាមរយៈការលក់ ទិញ អំណោយ ឬប្រទានកម្ម ។ល។ ក៏ត្រូវបានច្បាប់កំណត់។

ដីភោគៈ ឬដីដែលកាន់កាប់នេះ ត្រូវបានគេស្គាល់ជាទូទៅថា ដីមិនទាន់មានប័ណ្ណ ឬគ្មានប្លង់ដែលមានយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការពីថ្នាក់ស្រុក ខេត្ត ថ្នាក់ជាតិនៅពេលមានទំនាស់។ ម្ចាស់ដីភោគៈ ឬហៅថាភោគី ដូចជាម្ចាស់ដីស្រែ ដីចំការ ដីផ្ទះ ។ល។ ដែលមិនទាន់ត្រូវបានចុះបញ្ជី ជាប្រព័ន្ធក៏

មិនទាន់មានទិន្នន័យជាក់លាក់ថា មានភោគៈស្រប ឬមិនស្របច្បាប់ក្នុងប្រព័ន្ធអភិបាលកិច្ចដីនៅឡើយ។ ទិន្នន័យនៃការចុះបញ្ជីដីធ្លីគិតពីពេលចាប់ផ្តើម រហូតដល់ ដំណាច់ឆ្នាំ ២០១៨ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានចេញប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន ៥ ០៧៣ ០៣៤ ប័ណ្ណ ស្មើនឹង ៧២,៤៧% នៃក្បាលដីប៉ាន់ស្មានសរុប ៧លានក្បាលដី។ សិទ្ធិពលរដ្ឋ និងសិទ្ធិជនជាតិដើមភាគតិចលើដីរដ្ឋ ក៏មិនទាន់មានអភិបាលកិច្ចជាប្រពន្ធ័ ដែលកន្លងមកមានទំនាស់ថា គម្រោងសម្បទានដីសេដ្ឋកិច្ច ឬសម្បទានបានធ្វើឲ្យប៉ះពាល់ដល់អ្នកកាន់កាប់ដី ដែលគ្មានប័ណ្ណសម្គាល់សិទ្ធិ ឬដែលកាន់កាប់ជាក់ស្តែង ដោយសំអាងថាជាដីរដ្ឋសម្រាប់អភិវឌ្ឍន៍។

គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ លើការកាន់កាប់ដី ជលផល និងព្រៃឈើ ហៅកាត់ខ្លីថា វីជីជីធី (VGGT) កំណត់អំពី "ការកាន់កាប់ដីដោយ ធម្មានុរូប" និង "សិទ្ធិធម្មានុរូបទាំងអស់" ថា នៅពេលធ្វើច្បាប់ គោលនយោបាយ លិខិតបទដ្ឋានជាតិ រដ្ឋត្រូវគោរពដោយ ៖

១) កំណត់អត្តសញ្ញាណអ្នកកាន់កាប់ធម្មានុរូបដោយធ្វើការកត់ត្រាក្នុងបញ្ជី

២) ការពារសិទ្ធិធម្មានុរូបរបស់អ្នកកាន់កាប់

៣) សម្របសម្រួលឲ្យអ្នកកាន់កាប់ធម្មានុរូប ដោយមិនមាន ការបន្តុចបង្អាក់

៤) ក្នុងករណីមានការបំពានសិទ្ធិធម្មានុរូបលើដី នោះរដ្ឋមានយន្តការប្រកបដោយប្រសិទ្ធិភាពឲ្យម្ចាស់សិទ្ធិធម្មានុរូបរកយុត្តិធម៌តាមច្បាប់ រួចពីការគម្រាមកំហែង ឬអំពើពុករលួយទាំងឡាយ។

ក្របខណ្ឌគតិយុត្តជាធរមាន មិនចែងច្បាស់អំពី "សិទ្ធិធម្មានុរូបលើដី" នៃអ្នកកាន់កាប់ដូចក្នុង VGGT និងមិនមានការចុះបញ្ជី ឬលិខិតសម្គាល់អ្វីមួយចេញឲ្យអ្នកកាន់កាប់ធម្មានុរូបទេ។ សូម្បីតែ ភោគៈស្របច្បាប់ ក៏មិនមានការចុះបញ្ជីជាប្រពន្ធ័ដែរ ដោយសារប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជាទទួល ស្គាល់តែ "របបកម្មសិទ្ធិ" ប៉ុណ្ណោះ រួមទាំងជនជាតិដើមភាគតិចដែលរស់នៅជាសហគមន៍ និងប្រកបរបរកសិកម្មប្រពៃណីក្នុងតំបន់តាំងពីមុនច្បាប់ទៅទៀត។ របបកម្មសិទ្ធិដីក្នុងក្របខណ្ឌគតិយុត្តកម្ពុជាបច្ចុប្បន្ននេះ មានកម្មសិទ្ធិដីរបស់រដ្ឋ និងកម្មសិទ្ធិដីឯកជន។ ទាំងកម្មសិទ្ធិដីរបស់រដ្ឋ ទាំងកម្មសិទ្ធិដីឯកជនត្រូវចុះបញ្ជី និងចេញវិញ្ញាបនប័ត្រសម្គាល់សិទ្ធិរដ្ឋ (ប័ណ្ណកម្មសិទ្ធិ) ដូចគ្នា។

ក្រមរដ្ឋប្បវេណីចែងថា ដីដែលគ្មានម្ចាស់ជាដីរបស់រដ្ឋ។ ជាក់ស្តែង សូម្បីតែម្ចាស់ដីចំការ ឬ ស្រែ ឬផ្ទះភាគច្រើនក៏មិនទាន់បានចុះបញ្ជីជាកម្មសិទ្ធិនៅឡើយ។ នៅពេលមានការតតាំងគ្នារវាង ភ្នាក់ងាររដ្ឋ និងអ្នកកាន់កាប់ធម្មានុរូប ដែលចែងក្នុង VGGT ហើយគ្មានវិញ្ញាបនប័ត្រសម្គាល់សិទ្ធិ ឬ ហៅថា (ប័ណ្ណកម្មសិទ្ធិដី) នោះជាបញ្ហាគន្លឹះថា អ្នកណាជាម្ចាស់ដី? ក្នុងពេល ដែលរដ្ឋក៏មិនមានវិញ្ញា បនប័ត្រសម្គាល់សិទ្ធិរដ្ឋ (ប័ណ្ណកម្មសិទ្ធិដីរដ្ឋ) ហើយអ្នកកាន់កាប់ធម្មានុរូប ក៏មិនមានវិញ្ញាបនប័ត្រសម្គាល់សិទ្ធិដីឯកជន

(ប័ណ្ណកម្មសិទ្ធិដីឯកជន) ដែរនោះ? ដូចជាក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។ នៅ ក្នុង VGGT ចែងអំពីអ្នកកាន់កាប់ធម្មានុរូប ដែលមានសិទ្ធិធម្មានុរូបលើដីនោះដែរ ហើយរដ្ឋគួរមានលិខិតបទដ្ឋានច្បាប់ ឬក្រោមច្បាប់ និងយន្តការធ្វើអត្តសញ្ញាណ កត់ត្រា ការពារ និងសម្រួលដល់អ្នក កាន់កាប់ ឬភោគី ឬក៏ហៅថាអ្នកកាន់កាប់តាមប្រពៃណី ទំនៀមទម្លាប់ ឬហៅថា អ្នកកាប់ដីធម្មានុរូប ទាំងនោះ។ ដូចជាច្បាប់ភូមិបាល មាត្រា២៣ ចែងថា ក្រុមដែលមានស្រាប់ត្រូវបន្តការគ្រប់គ្រងអចលនវត្ថុ និងសហគមន៍របស់ខ្លួនតាមក្បួនខ្នាតប្រពៃណី និងតាមច្បាប់។ សំណួរសួរថា តើរដ្ឋមានអ្វីទៅ សម្គាល់ថាសិទ្ធិគ្រប់គ្រងតាមប្រពៃណីលើដីនិងសហគមន៍របស់គាត់? ប្រសិនមានទំនាស់? ហើយអ្នកកាន់កាប់មានឯកសារអ្វីតាមផ្លូវច្បាប់ដើម្បីជាភស្តុតាងសម្រាប់តតាំង ទាមទារសិទ្ធិប្រពៃណី ឬការ កាន់កាប់ដីជាធម្មានុរូប គ្មានប័ណ្ណ គ្មានឯកសារសម្គាល់?

ភោគៈស្របច្បាប់ គឺជាសិទ្ធិស្របច្បាប់ ដែលច្បាប់ភូមិបាល និងក្រមរដ្ឋប្បវេណីកំណត់ថា ស្របច្បាប់ ប៉ុន្តែ ក៏មិនឃើញមាននីតិវិធី ឬលិខិតបទដ្ឋាន ដែលចេញដោយរដ្ឋជូនភោគីជាប្រពន្ធ័ ឬជាទូទៅទេ។ ទំនាស់ភាគច្រើនកើតចេញពីភាពមិនច្បាស់លាស់នៃសិទ្ធិលើដី ភាពមិនច្បាស់លាស់ នៃឯកសារសម្គាល់ការកាន់កាប់ និងការបកស្រាយតម្លៃគតិយុត្តនៃឯកសារ ឬការមិនមានភាពច្បាស់លាស់នៃអភិបាលកិច្ចសិទ្ធិធម្មានុរូបលើដី។ ដើម្បីជាគំនិតក្នុងការធានាអភិបាលកិច្ចក្នុងវិស័យដីធ្លីដូច ក្នុងការសិក្សាប្រៀបធៀបនេះ គួរមានៈ

១- មានលិខិតបទដ្ឋានគតិយុត្តកំរិតណាមួយសម្រាប់ឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិ ដូចជាឃុំ/សង្កាត់ ដែលជាអ្នកតំណាងថ្នាក់មូលដ្ឋានឲ្យធ្វើការកំណត់អត្តសញ្ញាណ កត់ត្រាចូលបញ្ជីផ្លូវការនូវ "សិទ្ធិកាន់កាប់ដីធម្មានុរូប" និងយន្តការដោះស្រាយទំនាស់សិទ្ធិធម្មានុរូបស្របតាមក្របខណ្ឌជាតិបច្ចុប្បន្ន។

២- មានការកំណត់ព្រំទល់ដីគ្រប់ប្រភេទរបស់រដ្ឋច្បាស់លាស់ ដោយមានការចុះបញ្ជី ដែលមានប័ណ្ណ សម្គាល់សិទ្ធិរដ្ឋ និងគួរមានអភិបាលកិច្ចជាប្រពន្ធ័លើការកាន់កាប់ដីធម្មានុរូបលើដីនោះ ដែលក្នុង VGGT ចែងថា ជាការកាន់កាប់ និងសិទ្ធិធម្មានុរូបលើដី។ ការកាន់កាប់ដីធម្មានុរូប ទោះបីមិនមែនជា ផ្នែកមួយនៃលទ្ធកម្ម (ភោគអាចទទួលបាន) កម្មសិទ្ធិដូចច្បាប់ភូមិបាល ក៏គួរមានវិធានការធានាសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើទ្រព្យសម្បត្តិរដ្ឋដែរ។ ឧទាហរណ៍ ដីដែលអ្នកភូមិ ឬជនជាតិដើមភាគ តិចឃ្វាលគោ ក្របី ដីដែលធ្លាប់ធ្វើចម្ការវិលជុំក្នុងព្រៃ ដីព្រៃដែលជាប្រភពអាហារ ដីត្រពាំង ដីបឹង អូរ ស្រះ ។ល។ សុទ្ធតែជាដីដែលមានការកាន់កាប់ធម្មានុរូប ហើយមានទំនាក់ទំនងសិទ្ធិរវាងអ្នកកាន់កាប់ និងដីទាំងនោះ ដែលគាត់បានប្រើប្រាស់ ពឹងផ្អែកជាយូរហើយ តែសិទ្ធិនេះ មិនត្រូវបានចុះបញ្ជី តាមគោលការណ៍អភិបាលកិច្ចទេ ទោះបីច្បាប់ធានាក៏ដោយ។

៣- ការពន្លឿនការចុះបញ្ជីកម្មសិទ្ធិដីជាប្រព័ន្ធចំពោះដីផ្ទះ ស្រែ ចំការ ដីរដ្ឋ ក្នុងពេលតែមួយជាមួយនឹង ការចុះបញ្ជីសិទ្ធិប្រើប្រាស់នៃអ្នកកាន់កាប់ធម្មានុរូបលើទ្រព្យសម្បត្តិរដ្ឋដែរ។ សិទ្ធិធម្មានុរូបលើដីរដ្ឋ គឺជាសិទ្ធិមនុស្ស ដែលចែងក្នុង VGGT ពិសេសដីព្រៃ ដីដែលមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិឯកជន។

៤- ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងតួអង្គសំខាន់ៗឲ្យយល់ច្បាស់អំពីសិទ្ធិធម្មានុរូបលើដីតោគ: ស្របច្បាប់ជាប្រពន្ធ័។

៥- អប់រំផ្សព្វផ្សាយ បង្កើនការយល់ដឹងអំពីនីតិវិធីដាក់ពាក្យបណ្តឹង ការប្រមូលភស្តុតាង នៅពេលមាន ការរំលោភសិទ្ធិកាន់កាប់ធម្មានុរូបលើដីនោះ។


គាំទ្រមូលនិធិដោយ

សហភាពអឺរ៉ុប

សហការរៀបចំដោយ៖

Cambodian Center for Human Rights

Building Community Voices

The NGO Forum on Cambodia

C.W.D.C.C

actionaid